# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.............០១៣..............ក.ប/ប្រ.ក

## ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាពលេខាធិការដ្ឋានរបស់គណៈកម្មការប្រឹក្សាការងារ

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការប្រឹក្សាការងារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ
- បានឃើញប្រកាសលេខ០៦៨/១៤ ក.ប/ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ស្តីពីការផ្លាស់ប្តូរសមាសភាពសមាជិកគណៈកម្មការប្រឹក្សាការងារអាណត្តិទី៨
- យោងប្រកាសលេខ០៩៧/១៤ ក.ប/ប្រក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតលេខាធិការដ្ឋាន របស់គណៈកម្មការប្រឹក្សាការងារ
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពលេខាធិការដ្ឋានរបស់គណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សាត សមុទ្រ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | សេង សក្ដា | អគ្គនាយកការងារ | អនុប្រធាន |
| ៤-ឯកឧត្តម | ទេស រុក្ខាផល | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៥-ឯកឧត្តម | ហុង ជឿន | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៦-លោក | អ៊ិន ខេមរា | អគ្គនាយករងការងារ | សមាជិក |
| ៧-លោក | ប៉ុល ចាន់ដារ៉ា | អគ្គនាយករងការងារ | សមាជិក |
| ៨-លោក | គួច សុមាន | អនុប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៩-កញ្ញា | ថៃ ស៊ាងមាន | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ១០-លោក | ឡឿម សុក្រវិច្ឆ័យ | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ១១-លោក | កុយ ទេពដារាវុធ | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិកអចិន្ត្រៃយ៍ |
| ១២-លោក | អ៊ុក ចាន់ធូ | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៣-លោក | ហួន សឿរ | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៤-លោក | ខៀវ សាវុធ | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៥-លោក | ខេង សំបូរ | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៦-លោក | ជ្រុន ថេរ៉ាវង្ស | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៧-លោក | ស្រ៊ុន ចន្ទុល | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៨-លោក | និន វណ្ណះ | អនុប្រធានន.ផែនការ ស្ថិតិនិងនីតិកម្ម | សមាជិក |
| ១៩-លោក | សេង សុខហេង | អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២០-លោក | ជា ស៊ាងហុង | ប្រធានការិយាល័យវិវាទការងារទី៣ | សមាជិក |
| ២១-លោក | ហេង ម៉ិនថា | ប្រធានការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ | សមាជិក |

**ប្រការ ២.-**

លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលក្នុងកិច្ចការសិក្សាស្រាវជ្រាវអំពីបញ្ហាប្រាក់ឈ្នួលអប្បបរមាសមស្របសម្រាប់កម្មករនិយោជិត
- លើកផែនការថវិកាសម្រាប់អនុវត្តការងាររបស់គណៈកម្មការ
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយដៃគូសង្គម និងដៃគូអភិវឌ្ឍន៍នានា
- សម្របសម្រួលជាមួយអង្គការអន្តរជាតិខាងការងារ លើការងារជំនួយបច្ចេកទេស
- រៀបចំ និងចាត់ចែងរាល់កិច្ចប្រជុំពាក់ព័ន្ធនានា
- ធ្វើកំណត់ហេតុ និងរបាយការណ៍របស់កិច្ចប្រជុំនានា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៣.-**

ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំជំនួសតាមការប្រគល់ភារកិច្ចរបស់ប្រធាន។

**ប្រការ ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

-ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-គ្រប់សមាគមនិយោជក

-គ្រប់សហព័ន្ធសហជីព

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"

- ឯកសារ - កាលប្បវត្តិ